អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**BUREAU DES CO-JUGES D'INSTRUCTION**
**OFFICE OF THE CO-INVESTIGATING JUDGES**

ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១១

# សេចក្ដីប្រកាសព័ត៌មាន

ដោយអនុលោមតាមវិធាន ៥៦ (២) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សហចៅក្រមស៊ើបអង្កេតសូមជូនដំណឹងដល់សាធារណជនអំពីដំណើការវិវត្តន៍ ទាក់ទងនឹងសំណុំរឿង ០០៣ និង ០០៤។

នៅក្នុងស្មារតីនៃកិច្ចសហការដូចដែលមានកំណត់នៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតបានបង្កើតឲ្យមានជាក្រុមការងាររួមជាច្រើនក្រុម។ ភារកិច្ចបច្ចុប្បន្នរបស់ក្រុមការងារទាំងនេះគឺការពិនិត្យនិងវិភាគលើឯកសារនានាដែលមាននៅក្នុងសំណុំរឿង ជាពិសេសឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿង ០០១ និង ០០២។ ដូច្នេះ នៅក្នុងដំណាក់កាលបច្ចុប្បន្ននេះគឺមិនមានការចុះស៊ើបអង្កេតណាមួយកំពុងត្រូវបានធ្វើឡើយ។

សហចៅក្រមស៊ើបអង្កេតសង្ឃឹមថា សេចក្ដីប្រកាសព័ត៌មាននេះនឹងអាចបញ្ចៀសនូវរាល់ការយល់ខុស និងការបកស្រាយមិនត្រឹមត្រូវនានា ទាក់ទិននឹងស្ថានភាពបច្ចុប្បន្ននៃការងាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលនៅតែជាកិច្ចការសម្ងាត់នៅឡើយ។